# លក្ខខណ្ឌយោង

## ទីប្រឹក្សា/ជំនាញការក្នុងស្រុក រៀបចំក្របខណ្ឌ និង យន្តការតាមដាននិងវាយតម្លៃលើការអនុវត្ត គោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ

(Output Basis Assignment)

**ទីកន្លែងបម្រើការងារៈ** នាយកដ្ឋានគោលនយោបាយ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

### ១. សេចក្តីផ្តើមអំពីអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) ត្រូវបានបង្កើតឡើងតាមរយៈព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ អ.ស.ហ.។ អ.ស.ហ. មាននិយ័តករ និងអង្គភាពក្រោមឱវាទចំនួន ៨ រួមមាន÷ អគ្គលេខាធិការដ្ឋាន អ.ស.ហ., និយ័តករមូលបត្រកម្ពុជា, និយ័តករធានារ៉ាប់រងកម្ពុជា, និយ័តករសន្តិសុខសង្គម, និយ័តករបរធនបាលកិច្ច, និយ័តករគណនេយ្យនិងសវនកម្ម, និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ និងអង្គភាពសវនកម្មផ្ទៃក្នុង។ ជាមួយគ្នានេះ អគ្គ-លេខាធិការដ្ឋាន អ.ស.ហ. ជាសេនាធិការឱ្យអ.ស.ហ. មានតួនាទីនិងភារកិច្ចក្នុងការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគាររួមទាំងតាមដាន និងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តផងដែរ។

### ២. ពិពណ៌នាអំពីមូលហេតុនៃការរៀបចំក្របខណ្ឌ និងយន្តការប្រព័ន្ធតាមដាន និងវាយតម្លៃ

ដើម្បីអនុវត្តកិច្ចការនេះប្រកបដោយប្រសិទ្ធភាព, អគ្គលេខាធិការដ្ឋាន អ.ស.ហ. មានភាពចាំបាច់រៀបចំក្របខណ្ឌនិងយន្តការតាមដាន និងវាយតម្លៃរួមរបស់ អ.ស.ហ. ដែលពិនិត្យទៅលើវឌ្ឍនភាពនិងប្រសិទ្ធភាពនៃការរៀបចំ និងការអនុវត្តទិសដៅនិងកម្មវិធីការងាររបស់និយ័តករ និងអង្គភាពក្រោមឱវាទ អ.ស.ហ. សម្រាប់ឆ្នាំប្រតិបត្តិនីមួយៗឱ្យមានសង្គតិភាពទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំងសង្កេតលើការអនុវត្តជាក់ស្តែងតាមគ្រានីមួយៗ ដើម្បីស្វែងរកដំណោះស្រាយលើបញ្ហាប្រឈមដែលនឹងជួបប្រទះ។ បន្ថែមពីនេះ អគ្គលេខាធិការដ្ឋាន អ.ស.ហ. ក៏ត្រូវផ្តោតទៅលើការវាយតម្លៃអំពីទិដ្ឋភាពរួមនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំងពិនិត្យទៅលើស្ថានភាពទីផ្សារនៃវិស័យ និងអនុវិស័យ ដើម្បីរៀបចំទិសដៅនាពេលអនាគតក្នុងកម្រិតគោលនយោបាយ និងយុទ្ធសាស្ត្រផងដែរ។

## ៣. ការពិពណ៌នារួមអំពីមុខតំណែង

ដើម្បីធានាបាននូវប្រសិទ្ធភាពការងារពាក់ព័ន្ធនឹងកិច្ចការនេះ អគ្គលេខាធិការដ្ឋាន អ.ស.ហ. មានតម្រូវការទីប្រឹក្សា/ជំនាញការក្នុងស្រុក ដែលមានជំនាញឯកទេស និងសមត្ថភាពពាក់ព័ន្ធនឹងការរៀបចំក្របខណ្ឌ និង យន្តការតាមដាននិងវាយតម្លៃទៅលើគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងជួយកិច្ចការផ្សេងៗទៀតតាមការណែនាំរបស់អគ្គលេខាធិការដ្ឋាន អ.ស.ហ.។ ទីប្រឹក្សា/ជំនាញការក្នុងស្រុក នឹងត្រូវបំពេញការងារដូចខាងក្រោម÷

### ៣.១. តួនាទី និងការទទួលខុសត្រូវ÷

- ស្រាវជ្រាវឯកសារពាក់ព័ន្ធសំខាន់ៗរួមមានលិខិតបទដ្ឋានគតិយុត្តនានាដែលមានជាធរមាន និងធ្វើការសិក្សាអំពីការអនុវត្តរបស់ប្រទេសនានា (ជាជំនួយបន្ថែម) ដើម្បីជាមូលដ្ឋានក្នុងការរៀបចំ បង្កើតទម្រង់របាយការណ៍/របាយការណ៍ លទ្ធផលនៃការតាមដាន និងវាយតម្លៃការអនុវត្តទិសដៅ និងកម្មវិធីការងារ, រៀបចំនីតិវិធីប្រតិបត្តិស្តង់ដារ (Standard Operating Procedure-SOP) ស្តីពីយន្តការតាមដាន និងវាយតម្លៃទិសដៅ និងកម្មវិធីការងារ, រៀបចំនីតិវិធីប្រតិបត្តិស្តង់ដារ (Standard Operating Procedure-SOP) ស្តីពីយន្តការតាមដាន និងវាយតម្លៃគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ វិស័យហិរញ្ញវត្ថុមិនមែនធនាគារ និង សិក្សា/រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ (សេចក្តីព្រាងចុងក្រោយ)
- ប្រមូលព័ត៌មានចាំបាច់ពីមន្ត្រី និងភាគីពាក់ព័ន្ធ ដើម្បីសិក្សាពីបទពិសោធន៍នៃការអនុវត្តកន្លងមក ជាពិសេសឯកសារទម្រង់របាយការណ៍/របាយការណ៍ លទ្ធផលនៃការតាមដាន និងវាយតម្លៃការអនុវត្តទិសដៅ និងកម្មវិធីការងារ, រៀបចំនីតិវិធីប្រតិបត្តិស្តង់ដារ (Standard Operating Procedure-SOP) ស្តីពីយន្តការតាមដាន និងវាយតម្លៃទិសដៅនិងកម្មវិធីការងារ, រៀបចំនីតិវិធីប្រតិបត្តិស្តង់ដារ (Standard Operating Procedure-SOP) ស្តីពីយន្តការតាមដាន និងវាយតម្លៃគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ វិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងសិក្សា/រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ (សេចក្តីព្រាងចុងក្រោយ)
- ស្រាវជ្រាវបន្ថែម តាមការណែនាំរបស់អគ្គលេខាធិការដ្ឋាន អ.ស.ហ. និងកិច្ចប្រជុំពិភាក្សានានា
- ជួបប្រជុំជាមួយស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីទទួលបានធាតុចូល
- រៀបចំសេចក្តីព្រាងបឋម និងសេចក្តីព្រាងចុងក្រោយនៃឯកសារខាងលើ
- រៀបចំរបាយការណ៍វឌ្ឍនភាព និងរបាយការណ៍លទ្ធផល
- ធ្វើបទបង្ហាញដល់ក្រុមការងារ និងកែលម្អលើសេចក្តីព្រាង ដើម្បីឈានទៅដល់សេចក្តីព្រាងចុងក្រោយ
- ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. លើការរៀបចំឯកសារខាងលើ ។

## ៣.២. លទ្ធផលរំពឹងទុក

| ល.រ | លទ្ធផលរំពឹងទុក | ពេលវេលាអនុវត្ត |
|---|---|---|
| | **ដំណាក់កាលទី១** | |
| ១ | ➢ រៀបចំទម្រង់របាយការណ៍/របាយការណ៍លទ្ធផល នៃការតាមដាន និងវាយតម្លៃការអនុវត្តទិសដៅ និងកម្មវិធីការងារ<br>➢ រៀបចំទម្រង់របាយការណ៍/របាយការណ៍លទ្ធផលនៃការវិភាគម៉ាក្រូ-សេដ្ឋកិច្ច ស្ថានភាពវិស័យហិរញ្ញវត្ថុ និងគោលនយោបាយអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ពិសេសវិស័យហិរញ្ញវត្ថុមិនមែនធនាគារ<br>➢ រៀបចំទម្រង់របាយការណ៍/របាយការណ៍ លទ្ធផលនៃការតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ | ៣ខែ (បន្ទាប់ពីចុះកិច្ចសន្យា) |
| ២ | រៀបចំនីតិវិធីប្រតិបត្តិស្តង់ដារ(Standard Operating Procedure-SOP) ស្តីពីយន្តការតាមដាន និងវាយតម្លៃទិសដៅនិងកម្មវិធីការងារ, | ៣ខែ (កុម្ភៈ ២០២៣ ដល់មេសា២០២៣) |
| ៣ | រៀបចំនីតិវិធីប្រតិបត្តិស្តង់ដារ(Standard Operating Procedure-SOP) ស្តីពីយន្តការតាមដាន និងវាយតម្លៃគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ | ៤ខែ (ឧសភា ២០២៣ ដល់សីហា២០២៣) |
| | **ដំណាក់កាលទី២** | |
| ៤ | សិក្សា/រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ (សេចក្តីព្រាងចុងក្រោយ) | ៤ខែ (កញ្ញា - ធ្នូ ឆ្នាំ ២០២៣) |

ទីប្រឹក្សា/ជំនាញការក្នុងស្រុក នឹងស្ថិតនៅក្រោមការដឹកនាំរបស់អគ្គលេខាធិការដ្ឋាន អ.ស.ហ. និងអាចទទួលបានការបណ្តុះបណ្តាលបន្ថែមលើឯកទេសកម្មវិភាគ និងរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

## ៣.៣. គុណវុឌ្ឍិរបស់ទីប្រឹក្សា/ជំនាញការក្នុងស្រុក

- មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, គោលនយោបាយសាធារណៈ ឬ សញ្ញាបត្រជំនាញប្រហាក់ប្រហែល,
- មានបទពិសោធន៍ការងារយ៉ាងហោច ៥ឆ្នាំ ពាក់ព័ន្ធនឹងការងាររៀបចំផែនការសកម្មភាព និងផែនការថវិកា
- មានបទពិសោធន៍ការងារយ៉ាងហោច ៥ ឆ្នាំលើការងារតាមដាន និងវាយតម្លៃ ការងារសិក្សាស្រាវជ្រាវលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ គោលនយោបាយហិរញ្ញវត្ថុ

- មានសមត្ថភាពល្អក្នុងការសរសេររបាយការណ៍ជាភាសាខ្មែរ និងភាសាអង់គ្លេសស្ទាត់ជំនាញ និង
- មានសមត្ថភាពក្នុងការធ្វើបទបង្ហាញ ។

**៤. របាយការណ៍**

ទីប្រឹក្សា/ ជំនាញការក្នុងស្រុក នឹងត្រូវធ្វើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តការងារប្រចាំខែ ត្រីមាស ឆមាស និង ដំណាច់ឆ្នាំជូនអគ្គលេខាធិការដ្ឋាន អ.ស.ហ. និង អ.គ.ហ. ។

**៥. រយៈពេលធ្វើការ**

កិច្ចសន្យាការងារមានរយៈពេល ១២ខែ នឹងអាចបន្តបានតាមស្ថានភាពជាក់ស្តែង ។

**៦. មធ្យោបាយភាសា**

ភាសាខ្មែរ និងអង់គ្លេសត្រូវប្រើប្រាស់សម្រាប់ការទំនាក់ទំនង ការរៀបចំរបាយការណ៍ និងឯកសារផ្សេងៗ ។

**៧. ទីតាំងសម្រាប់បំពេញការងារ**

ទីប្រឹក្សា/ ជំនាញការក្នុងស្រុក នឹងតម្រូវឱ្យធ្វើការនៅនាយកដ្ឋានគោលនយោបាយ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. ដែលមានអាសយដ្ឋាននៅផ្លូវលេខ ៤៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

**៨. ការរៀបចំឡជីស្ទីក**

កៅអី និងតុការិយាល័យ ប្រព័ន្ធអ៊ីនធឺណេត និងសម្ភារៈផ្គត់ផ្គង់ការិយាល័យផ្សេងៗទៀតនឹងត្រូវផ្តល់ជូន ទីប្រឹក្សា/ ជំនាញការក្នុងស្រុក។ ទីប្រឹក្សា/ ជំនាញការក្នុងស្រុកមិនត្រូវបានលើកទឹកចិត្តឱ្យធ្វើការ ឬទំនាក់ទំនងសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន ក្នុងកំឡុងពេលធ្វើការនោះទេ។